# ធម្មកថា

## របស់ព្រះតេជព្រះគុណបណ្ឌិតហុក-សាវណ្ណ
## អំពីធម៌របស់ព្រះពុទ្ធដឹកនាំអ្នកប្រតិបត្តិឲ្យចេញចាកទុក្ខ

web site: hoksavann.org

ថ្ងៃទី៦ មេសា ២០០៥

ព្រះពុទ្ធជាមនុស្សជាតិ ទ្រង់ប្រសូតមានព្រះមាតាបិតាស្ថិតនៅលើផែនដី ហើយដែលនាំឲ្យព្រះអង្គមានប្រភេទប្លែកពីមនុស្សធម្មតានោះ គឺត្រង់ព្រះអង្គបានត្រាស់ជាព្រះពុទ្ធ ឃើញអរិយសច្ចៈជាធម៌សំរាប់ចម្លងមនុស្សសត្វដែលប្រតិបត្តិតាមឲ្យចេញចាកទុក្ខ ។ ព្រះអង្គត្រាស់ដឹងនូវលោក ដែលហៅថាលោកវិទូ ប្រែថាព្រះអង្គត្រាស់ដឹងនូវលោកបីគឺ សង្ខារលោក បានដល់ព្រះអាទិត្យ ព្រះចន្ទ ផែនដីជាដើម, សត្វលោក បានដល់មនុស្សសត្វដែលមានចិត្តវិញ្ញាណ, ឱកាសលោក បានដល់រចនាសម្ព័ន្ធរបស់លោកធាតុឬចក្រវាឡ ដែលចលនាទាក់ទងតាមច្បាប់ធម្មជាតិនិងច្បាប់ក្នុងកម្មផល គ្មានអ្នកណាបង្កើតឡើយ ។ ព្រះអង្គត្រាស់ដឹងនូវលោកធាតុឬចក្រវាឡទាំងអស់ តែព្រះអង្គពុំសំដែងព្រោះពុំមានប្រយោជន៍ក្នុងការរំដោះទុក្ខមនុស្សសត្វ ។ ព្រះអង្គសំដែងដោយយកហេតុបច្ច័យនៃលោកខាងក្រៅមកប្រៀបធៀបនឹងហេតុបច្ច័យនៃលោកក្នុងខ្លួនយើងថា លោកខាងក្រៅក៏ដូចជាលោកក្នុងខ្លួនយើងដែរ ។

ព្រះពុទ្ធប្រោសមនុស្សសត្វដោយការសំដែងធម៌ទេសនា បង្ហាញហេតុផលឲ្យគេពិចារណា ហើយសំរេចចិត្តជឿនិងប្រតិបត្តិតាមដោយខ្លួនគេ ។ ពាក្យថា ព្រះពុទ្ធសំដែងធម៌ប្រោសមនុស្សសត្វ ដែលមានឧបនិស្ស័យដែលគួរទុន្មានបាន គឺមនុស្សសត្វដែលធ្លាប់ធ្វើទានរក្សាសីលចំរើនភាវនាពីមុនមក (ទានូបនិស្ស័យ សីលូបនិស្ស័យ ភាវនូបនិស្ស័យ) មនុស្សសត្វគ្រប់ប្រភេទនេះ អាចទទួលធម៌ទេសនារបស់ព្រះអង្គយកទៅប្រតិបត្តិបាន ។ រោគផ្លូវចិត្តរបស់មនុស្សសត្វ បានដល់លោភៈ ទោសៈ មោហៈ ជាឫសគល់អកុសល ដូច្នេះថ្នាំគឺធម្មោសថឱសថ គឺព្រះធម៌ដែលត្រូវយកមកបំបាត់រោគទាំងនោះ បានដល់ទានសីលភាវនាហ្នឹងឯង ។ ទានសិលភាវនានេះសំរាប់ធ្វើឲ្យសង្គមមនុស្សរស់នៅជាមួយគ្នាបានសុខសាន្ត ។ ដើម្បីឲ្យសង្គមមនុស្សស្រឡាញ់រាប់អានគ្នា ព្រះសម្ពុទ្ធបង្រៀនឲ្យមនុស្សធ្វើទាន ជួយសង្គ្រោះគ្នាដោយទ្រព្យសម្បត្តិដោយគំនិតបញ្ញា គឺជួយឃិតយោងអ្នកទន់ខ្សោយឲ្យរស់នៅក្នុងសង្គមបានសុខស្រួលផង ។ ដើម្បីកុំឲ្យមនុស្សនិងសង្គមមនុស្សបៀតបៀនគ្នា ព្រះពុទ្ធបង្រៀនមនុស្សរក្សាសីល ដោយឲ្យផ្សាយមេត្តាចិត្តនិងករុណាចិត្តអាណិតអាសូរដល់គ្នាទៅវិញទៅមក ។ ដើម្បីឲ្យមនុស្សនិងសង្គមមនុស្សទុកចិត្តគ្នាសាមគ្គីគ្នា ព្រះពុទ្ធបង្រៀនឲ្យមនុស្សអប់រំផ្លូវចិត្តឲ្យបានល្អកុំលំអៀងព្រោះស្រឡាញ់ព្រោះស្អប់ព្រោះភ័យខ្លាចព្រោះវង្វេង ពុំដឹងការពិតឡើយ ។ ខ្ពស់ពីនេះទៅទៀត ដើម្បីឲ្យផុតទុក្ខពីជាតិជរាព្យាធិមរណៈ ត្រូវប្រតិបត្តិតាមសីលសមាធិបញ្ញា ឬទានសីលភាវនានេះឲ្យបានម៉ត់ចត់បំផុត។ ព្រះពុទ្ធបានណែនាំថា អំពើអាក្រក់នាំឲ្យមានទុក្ខត្រូវលះបង់ អំពើល្អនាំឲ្យបានសុខត្រូវធ្វើឲ្យកើតច្រើនឡើង ។ ហេតុផលអាក្រក់និងល្អនេះ មាននៅក្នុងលោកជានិច្ច ព្រះពុទ្ធបានឃើញការពិតនេះ យកមកសំដែងប្រាប់មនុស្សសត្វទាំងអស់គ្នា ។ ក្នុងន័យនេះបញ្ជាក់ថា ការពិតនៅជាការពិតពុំមែនរឿងជឿឬពុំជឿឡើយ គឺធ្វើល្អបានផលល្អធ្វើអាក្រក់បានផលអាក្រក់ទៅតាមអំពើដែលខ្លួនបានប្រព្រឹត្ត ។ ព្រះពុទ្ធជាអ្នកបង្ហាញផ្លូវ ចំណែកមនុស្សសត្វត្រូវដើរដោយខ្លួនឯង ។

ធម៌របស់ព្រះពុទ្ធជាសច្ចធម៌ មានតថភាពដែលមនុស្សគ្រប់រូបគ្រប់ជាតិសាសន៍អាចយកមកពិសោធន៍ឃើញការពិតដោយខ្លួនឯង (បច្ចត្តំ វេទិតព្វោ) ។៚